**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៣៩ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## សូចនាករតាមដានរួមគ្នា ឆ្នាំ ២០១៤-២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យអនុវត្ត នូវសូចនាករតាមដានរួមគ្នា ឆ្នាំ ២០១៤-២០១៨ ដូចមានចែងក្នុងតារាងភ្ជាប់នឹងសេចក្ដីសម្រេចនេះ ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិសរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក៏ដូចជាដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ និងយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ។

**ប្រការ ២.-**

ប្រគល់ភារកិច្ចជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់** អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួល និងតាមដានការអនុវត្តសូចនាករតាមដានរួមគ្នា ហើយត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្ត ជូន**សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និងផ្តល់អនុសាសន៍ ។

**ប្រការ ៣.-**

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមការគ្រប់គ្រងរបស់ឯកឧត្តម រដ្ឋមន្ត្រីប្រតិភូ **ឈៀង យ៉ាណារ៉ា** ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋាន សម្រាប់ដឹកនាំការអនុវត្តសូចនាករទាំងនេះ ដោយត្រូវសហការជាមួយបណ្តាក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ។ លេខាធិការដ្ឋានត្រូវរាយការណ៍អំពីវឌ្ឍនភាពការងារប្រចាំឆ្នាំ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់** ។

**ប្រការ ៤.-**

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២ ប្រការ ៣ និងប្រការ ៤ «ដើម្បីអនុវត្ត»*
- *ឯកសារ-កាលប្បវត្តិ*

# សូចនាករតាមដានរួមគ្នា ២០១៤-២០១៨

ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី៣ (កថាខ័ណ្ឌទី ១០) ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺ កសាងសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាពនិងសមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការការពារបរិស្ថាន ការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងមានភោសិការផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ ក្នុងឋានៈជាសមាជិកពេញសិទ្ធិ និងស្មើសិទ្ធិនៅក្នុងសហគមន៍អន្តរជាតិ ។

ផ្អែកលើគោលការណ៍គណនេយ្យភាពទ្វេទិសដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ សូចនាករតាមដានរួមគ្នា គឺជាក្របខណ្ឌសម្រាប់កំណត់គោលដៅរយៈពេលមធ្យម ដែលជាអាទិភាពក្នុងយុទ្ធសាស្ត្រចតុកោណ ។ ធាតុចេញ និងសូចនាករ ដែលបានឯកភាពក្នុងក្រុមការងារបច្ចេកទេសចម្រុះ គឺជាមូលដ្ឋានសម្រាប់ណែនាំការអនុវត្តសកម្មភាពសម្រាប់ឆ្នាំ ២០១៤-២០១៥ ។ សូចនាករតាមដានរួមគ្នាដែលបានបង្ហាញក្នុងឯកសារនេះ ហើយដែលបានតម្រឹមជាមួយនឹងវិស័យអាទិភាពទាំង ៤ នៃយុទ្ធសាស្ត្រចតុកោណ (កថាខ័ណ្ឌទី ១៤) គឺជាអាទិភាពខ្ពស់បំផុត ដែលរាជរដ្ឋាភិបាលប្តេជ្ញាអនុវត្ត ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។

| យុទ្ធផល ២០១៤-២០១៨ | ធាតុចេញ ២០១៤-២០១៥ | សូចនាករធាតុចេញ ២០១៤-២០១៥ |
|---|---|---|
| **ស្នូលនៃយុទ្ធសាស្ត្រចតុកោណ : អភិបាលកិច្ចល្អ** - យុទ្ធសាស្ត្រចតុកោណ (កថាខ័ណ្ឌទី ១៤-៤) បានផ្តល់អាទិភាពទៅលើ ÷ ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ ១). ការបន្តអនុវត្តការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ សុចរិតភាព តម្លាភាព និងគណនេយ្យភាព ។ ២). ការបន្ត អនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យ ដើម្បីបង្កិតសេវាសាធារណៈឱ្យជិតប្រជាជន លើកកម្ពស់កិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងធានាបាននូវតុល្យភាពក្នុងការអនុវត្តអំណាច ។ ៣). ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាប្រសិទ្ធភាពក្នុងការវិភាជ និងការប្រើប្រាស់ថវិកា ។ ៤) ការបង្កើនភាពទាក់ទាញចំពោះការវិនិយោគ ក្នុងនោះ មានការកាត់បន្ថយថ្លៃដើម និងរបាំងធុរកិច្ច ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ ការពង្រឹងភាពជឿទុកចិត្ត និងភាពអាចព្យាករប្រមាណបានក្នុងការធ្វើធុរកិច្ច ព្រមទាំងការផ្តោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស ។ | | |
| **ការកែទម្រង់ច្បាប់ និងតុលាការ**<br><br>សេវាយុត្តិធម៌ និងឱកាសទទួលបានយុត្តិធម៌ត្រូវបានធ្វើឱ្យប្រសើរឡើង | ១. ការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការត្រូវបានបង្កើតឡើងស្របតាមកំណែទម្រង់ និងក្របខណ្ឌច្បាប់ថ្មី ហើយវិស័យយុត្តិធម៌ និងក្របខណ្ឌច្បាប់ និងគោលនយោបាយត្រូវបានធ្វើឱ្យប្រសើរឡើង ដោយមានការប្រឹក្សាយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ | ១.១. វឌ្ឍនភាពឆ្ពោះទៅការបង្កើតលិខិតបទដ្ឋានដែលតម្រូវដោយច្បាប់មូលដ្ឋានទាំង៣<br>១.២ ថវិកាដែលផ្តល់សម្រាប់ក្រសួងយុត្តិធម៌ និងប្រព័ន្ធតុលាការ ត្រូវបង្កើនឡើង<br>១.៣. គោលនយោបាយស្តីពីជំនួយផ្នែកច្បាប់ត្រូវបានរៀបចំឡើង ផ្តល់ថវិកា និងត្រូវបានអនុម័ត |
| | ២. ការគ្រប់គ្រងរឿងក្តី ត្រូវបានធ្វើឱ្យប្រសើរឡើង | ២.១. ភាគរយនៃការឃ្លាំមើលតុលាការ និងការរាយការណ៍ (ក្នុងរបាយការណ៍រដ្ឋបាលប្រចាំ |

| លទ្ធផល ២០១៤-២០១៨ | ធាតុចេញ ២០១៤-២០១៥ | សូចនាករធាតុចេញ ២០១៤-២០១៥ |
|---|---|---|
| | ៣.វិធានការជំនួស និងវិធានការមិនឃុំខ្លួន និងការកាត់ទោសត្រូវបានអនុវត្ត (ឬអនុវត្តសាកល្បង) | (ត្រីមាស) ស្តីពីការអនុវត្តការចុះបញ្ជីគុណការ ត្រូវកើនឡើង<br>២.២ ចំនួនសាលាដំបូងដែលប្រើប្រាស់មូលដ្ឋានទិន្នន័យរឿងក្តីព្រហ្មទណ្ឌ ត្រូវកើនឡើង<br>២.៣. ចំនួនអ្នកទោសដែលមានសាលក្រមស្ថាពរដែលអាចអនុវត្តបាន ត្រូវកើនឡើង<br>២.៤. ចំនួនសាលក្រមស្ថាពរដែលជ្រើសរើស ត្រូវបានចងក្រង និងផ្សព្វផ្សាយ<br>៣.១. ចំនួននៃការកាត់ទោសមិនដាក់ពន្ធនាគារសម្រាប់ការចោទប្រកាន់ពីបទលហុត្រូវកើនឡើង<br>៣.២. ចំនួនអ្នកដែលត្រូវឃុំខ្លួនមុនពេលជំនុំជំរះ ត្រូវថយចុះ |
| **ការកែទម្រង់រដ្ឋបាលសាធារណៈ**<br><br>រដ្ឋបាលសាធារណៈកាន់តែមានគម្លាភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ក្នុងការផ្តល់សេវាសាធារណៈ | ១. ផែនការសកម្មភាពសម្រាប់ការកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត<br>២. គោលនយោបាយប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ត្រូវបានរៀបចំប្រកបដោយសង្គតិភាព មានភាពឆ្លើយតប មានសមធម៌ និងផលិតភាព<br>៣. ការបើកបៀវត្សមន្ត្រីរាជការតាមរយៈធនាគារ នាចុងឆ្នាំ ២០១៤<br>៤. ឯកសារណែនាំស្តីពីការអភិវឌ្ឍសមត្ថភាព សម្រាប់អង្គភាពគ្រប់គ្រងធនធានមនុស្សនៃក្រសួងនិងស្ថាប័ន ត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>៥. ឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ ផែនការ និងយន្តការអភិវឌ្ឍធនធានមនុស្ស ត្រូវបានរៀបចំ និងអនុវត្ត<br>៦. ស្តង់ដារសេវាសាធារណៈត្រូវបានផ្សព្វផ្សាយនិងជំរុញការអនុវត្ត | ផែនការសកម្មភាពសម្រាប់ការកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុម័តក្នុងឆ្នាំ ២០១៤ ផែនការសកម្មភាពនេះ គ្របដណ្តប់លើការងារដូចខាងក្រោម ÷<br>- ការកែទម្រង់ប្រព័ន្ធបៀវត្ស<br>- ស្តង់ដារសេវាសាធារណៈ<br>- ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស |

| លទ្ធផល ២០១៤-២០១៨ | ធាតុចេញ ២០១៤-២០១៥ | សូចនាករធាតុចេញ ២០១៤-២០១៥ |
|---|---|---|
| **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**<br><br>ការបង្កើតសេវាសាធារណៈឱ្យជិតប្រជាពលរដ្ឋ តាមរយៈការបង្កើនសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលក្រុង និងស្រុក | ១. ក្របខណ្ឌច្បាប់ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង ដើម្បីប្រមូលចំណូលផ្ទាល់របស់ខ្លួន<br>២. ដំណើរការនៃការចាត់ចែងមុខងារឡើងវិញ ត្រូវបានអនុវត្ត ។ កិច្ចការនេះនាំទៅដល់ការផ្ទេរមុខងារ មន្ត្រី និងធនធាន ពីរដ្ឋបាលថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>៣. ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមត្រូវបានអនុវត្ត | ១.១. ត្រឹមឆ្នាំ ២០១៥ រដ្ឋបាលថ្នាក់ក្រោមជាតិប្រមូលចំណូលមិនមែនសារពើពន្ធ បានយ៉ាងតិច ៣ % នៃថវិការបស់ខ្លួន<br>២.១. ត្រឹមឆ្នាំ ២០១៥ ក្រសួងពាក់ព័ន្ធផ្ទេរមុខងារសំខាន់យ៉ាងតិចចំនួន ២ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមជាមួយមន្ត្រី និងធនធានចាំបាច់ ដើម្បីបំពេញមុខងារ<br>៣.១. ត្រឹមឆ្នាំ ២០១៥ ឃុំ សង្កាត់ទាំងអស់ក្នុងស្រុកចំនួន ៨០ នៅជនបទ បានអនុវត្តសកម្មភាពស្តីពីគណនេយ្យភាពសង្គម រួមទាំងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ និងការតាមដានរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តផែនការសកម្មភាពស្តីពីគណនេយ្យភាព |
| **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**<br><br>ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាមួយនឹងភាពជឿទុកចិត្តលើថវិកាប្រកបដោយចីរភាព និងការពង្រឹងទំនាក់ទំនងរវាងគណនេយ្យភាពថវិកា និងគោលនយោបាយថវិកា | ១. ការបន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា<br>២. ការកែលម្អគណនេយ្យភាពថវិកា ជាមួយនឹងការបន្តបង្កើនភាពជឿទុកចិត្តបាន និងបន្ទាត់គណនេយ្យភាពនៃថវិកា<br>៣. ការបន្តកែលម្អទំនាក់ទំនងក្នុងគោលនយោបាយថវិកា | ១.១. ក្រសួងយ៉ាងតិច ១០ បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា<br>១.២. របាយការណ៍ស្តីពីគណនេយ្យ និងហិរញ្ញវត្ថុ (ប្រចាំខែ ត្រីមាស ឆ្នាំ) ត្រូវបានរៀបចំទាន់ពេលវេលា និងផ្សព្វផ្សាយជាសាធារណៈ<br>១.៣. ស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ ត្រូវបានអនុវត្តនៅក្នុងស្តង់ដារគណនេយ្យ និងរបាយការណ៍<br>២.១. ចំណូលក្នុងស្រុកប្រចាំឆ្នាំ កើនឡើង ០,៥ % នៃ ផ.ស.ស<br>២.២. ការអនុវត្តចំណូល សម្រេចបានក្នុងរង្វង់ ៥% ធៀបនឹងថវិកាដែលបានអនុម័ត<br>២.៣. ការអនុវត្តចំណាយ សម្រេចបានក្នុងរង្វង់ ៥% ធៀបនឹងថវិកាដែលបានអនុម័ត<br>២.៤. សន្និធិបំណុលតិចជាង ២%<br>២.៥. ចំណាត់ថ្នាក់ថវិកា យ៉ាងតិច ៣ ប្រភេទ ត្រូវបានអនុវត្តយ៉ាងពេញលេញ<br>២.៦. ការអនុវត្តថវិកា មានភាពអាចទស្សន៍ទាយជាមុន និងមានប្រសិទ្ធភាព<br>៣.១. ក្រសួងយ៉ាងតិចចំនួន ១០ អនុវត្តពេញលេញ នូវថវិកាតាមកម្មវិធី និងអនុវត្តសាកល្បងអង្គភាពថវិកា |

| លទ្ធផល<br>២០១៤-២០១៨ | ផលចេញ<br>២០១៤-២០១៥ | សូចនាករផលចេញ<br>២០១៤-២០១៥ |
|---|---|---|
| **សុខដុមនីយកម្ម និងភាពជាដៃគូ**<br>ការសម្រេចគោលដៅអភិវឌ្ឍន៍នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ដែលឆ្លើយតបនឹងគោលនយោបាយ និងអាទិភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជាការអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូ | ១.១. បង្កើនសមាមាត្រហិរញ្ញប្បទាន ដែលផ្តល់តាមរយៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី<br>១.២. បង្កើនសមាមាត្រផ្តល់ហិរញ្ញប្បទាន ដែលប្រើប្រាស់ប្រព័ន្ធលទ្ធកម្មរបស់រាជរដ្ឋាភិបាល<br>២. តម្លាភាពថវិកាដើម្បីបង្កើនភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ÷<br>២.១. បង្កើនសមាមាត្រហិរញ្ញប្បទានដែលបានរំលេចក្នុងថវិកា និងផែនការរបស់រាជរដ្ឋាភិបាល<br>២.២. ការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រដល់អាទិភាពនៃកិច្ចអភិវឌ្ឍន៍ ត្រូវផ្អែកលើធនធានដែលមាន គិតទាំងធនធានសហប្រតិបត្តិការ និងធនធានរបស់រាជរដ្ឋាភិបាល<br>៣. ជំរុញប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះ និងការតម្រឹមជាមួយនឹងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ | ១.១. ភាគរយនៃហិរញ្ញប្បទាន ដែលផ្តល់តាមរយៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី (ទិន្នន័យមូលដ្ឋាន ២៨ % គោលដៅ ៣០ % ចុងឆ្នាំ ២០១៥)<br>១.២ ភាគរយនៃហិរញ្ញប្បទាន ដែលប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (ទិន្នន័យមូលដ្ឋាន ២០ % គោលដៅ ២២ % ចុងឆ្នាំ ២០១៥)<br>២.១. ភាគរយហិរញ្ញប្បទានដែលរំលេចក្នុងផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ (ទិន្នន័យមូលដ្ឋាន ៣២% គោលដៅ ៣៥ % ចុងឆ្នាំ ២០១៥)<br>២.២. ធនធានដែលមានទាំងអស់នឹងរំលេចក្នុងផែនការយុទ្ធសាស្ត្រថវិកា ស្របតាមផែនការសកម្មភាពស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសូចនាករតាមដានរួមគ្នាដែលបានឯកភាព (សូចនាករនៃក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)<br>៣.១ ការពិនិត្យឡើងវិញ នូវក្រុមការងារបច្ចេកទេសចម្រុះ និងការអនុវត្តនូវអនុសាសន៍ស្តីពីការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រុមការងារបច្ចេកទេសចម្រុះ ក្នុងឆ្នាំ ២០១៤ |
| **ផែនការ និងការកាត់បន្ថយភាពក្រីក្រ**<br>ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ ត្រូវបានអនុម័ត ដើម្បីឈានទៅសម្រេច នូវគោលដៅអភិវឌ្ឍន៍ជាតិ រួមទាំងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ហើយការវាយតម្លៃវឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រនេះ នឹងផ្អែកលើគុណភាពទិន្នន័យ និងស្ថិតិ | ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានរៀបចំបញ្ចប់ អនុម័ត និងអនុវត្ត ជាមួយនឹងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល ហើយយន្តការផែនការ និងការតាមដានវាយតម្លៃត្រូវបានពង្រឹង | ១.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មី ២០១៤-២០១៨ ត្រូវបានរៀបចំ<br>១.២. កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល ត្រូវបានរៀបចំ និងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុម័ត ។ កម្មវិធីវិនិយោគសាធារណៈគឺជាធាតុចូលសម្រាប់រៀបចំថវិកាជាតិ<br>១.៣. របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងរបាយការណ៍ប្រចាំឆ្នាំនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>១.៤. របាយការណ៍របស់ក្រុមការងារថ្នាក់ជាតិស្តីពីការតាមដាននិងវាយតម្លៃ ត្រូវបានរៀបចំ ដោយផ្អែកលើលទ្ធផលនៃកិច្ចប្រជុំទាំង ៤ លើក<br>១.៥. របាយការណ៍ខ្លីស្តីពីវឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាទី ១ ត្រូវបានរៀបចំ<br>១.៦. របាយការណ៍ស្តីពីអត្តសញ្ញាណជនក្រីក្រត្រូវបានរៀបចំជាទៀងទាត់ |

| [illegible]<br>២០១៤-២០១៨ | [illegible]<br>២០១៤-២០១៥ | លទ្ធផលរំពឹងទុក<br>២០១៤-២០១៥ |
|---|---|---|
| **វិស័យព្រៃឈើ**<br>ការគ្រប់គ្រង និងការអភិរក្សព្រៃឈើប្រកបដោយចីរភាព សម្រាប់ចូលរួមកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច (១,១ % នៃផលិតផលក្នុងស្រុកសរុប) | ១. សហគមន៍ព្រៃឈើត្រូវបានពង្រឹង និងបង្កើនចំនួន<br>២. ការដាំដើមឈើឡើងវិញ លើដីគ្មានព្រៃ ឬ ដីព្រៃរិចរិល<br>៣. ការបង្កើតតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ<br>៤. កម្មវិធីហិរញ្ញប្បទានក្នុងវិស័យព្រៃឈើប្រកបដោយចីរភាព | ១.១. ការប្រកាសបង្កើតសហគមន៍ព្រៃឈើថ្មីចំនួន ៦២ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>១.២. សហគមន៍ព្រៃឈើ ១០០ កន្លែង បានចុះកិច្ចព្រមព្រៀងជាមួយខណ្ឌរដ្ឋបាលព្រៃឈើ<br>១.៣. ផែនការគ្រប់គ្រងព្រៃសហគមន៍ ចំនួន ១៥០ កន្លែង អនុម័តពីរដ្ឋបាលព្រៃឈើ<br>២.១. ចម្ការឈើប្រភេទពាណិជ្ជកម្ម ចំនួន ៥០.០០០ ហិកតា<br>២.២. កូនឈើ ចំនួន ២០ លានដើម ត្រូវបានចែកចាយ សម្រាប់ការដាំឈើព្រៃ<br>២.៣. ការសាកល្បងកសិរុក្ខកម្ម ចំនួន ៤ កន្លែង ត្រូវបានបង្កើត<br>៣.១. តំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ យ៉ាងតិច ១០០.០០០ ហិកតា ត្រូវបានបង្កើត<br>៤.១. កិច្ចព្រមព្រៀងមួយស្តីពីការលក់ឥណទានកាបោន បានចុះហត្ថលេខា (ផ្អែកលើផ្ទៃទីផ្សារ) |
| **វិស័យជលផល**<br>ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកធានានូវសន្តិសុខស្បៀង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងគោលដៅលើកកម្ពស់ជីវភាពប្រជាជន និងវិបុលភាពរបស់ប្រទេស | ១. បរិមាណផលត្រីទឹកសាប និងទឹកប្រៃ រក្សាបានក្នុងកម្រិតថេរ តាមរយៈការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ប្រកបដោយចីរភាព ដោយអនុវត្តគោលការណ៍ស្តីពីបរិស្ថាន | ១.១. ផលត្រីចាប់ពីធម្មជាតិរក្សាបានកម្រិតចីរភាព ក្នុងបរិមាណយ៉ាងតិច ៥០០ ពាន់តោន ក្នុង ១ ឆ្នាំ ហើយផលត្រីចាប់តាមវាលស្រែកើនឡើង ១៥ % ក្នុង ១ ឆ្នាំ រហូតដល់ ១៨៤ ពាន់តោន នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br>១.២. ផ្ទៃដីព្រៃលិចទឹក ចំនួន ១០% (៩៣.២១៤ ហិកតា) និងព្រៃកោងកាង យ៉ាងតិច ២៥% (១០.១៦៦ ហិកតា) នៃផ្ទៃព្រៃសរុប ត្រូវបានការពារ តាមរយៈការបោះបង្គោលការពារ នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br>១.៣. អន្លង់ជ្រៅៗចំនួន ៣០ ត្រូវបានការពារប្រកបដោយប្រសិទ្ធភាព នៅត្រឹមដំណាច់ឆ្នាំ២០១៥<br>១.៤. សហគមន៍នេសាទ ចំនួន ២៨៩ ដែលបានចុះបញ្ជី ត្រូវបានពង្រឹង និងអនុវត្តពេញលេញ នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br>១.៥. ឃុំ- សង្កាត់ ចំនួន ៨០០ មានសហគមន៍ស្រះជម្រកត្រី ប្រកបដោយចីរភាព និងប្រសិទ្ធភាព នៅត្រឹមដំណាច់ឆ្នាំ ២០១៥ |

| លទ្ធផល<br>២០១៤-២០១៨ | [illegible]<br>២០១៤-២០១៥ | សូចនាករលទ្ធផល<br>២០១៤-២០១៥ |
| --- | --- | --- |
| | ២. ផលិតផលវារីវប្បកម្មទឹកសាប និងទឹកប្រៃ មានការកើនឡើង ដោយអនុវត្តគោលការណ៍បរិស្ថាន និងផ្តល់ផលប្រយោជន៍ដល់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ និងសហគ្រាសធុនតូច និងមធ្យម<br>៣. ការគាំទ្រ សម្រាប់លើកកម្ពស់គុណភាព និងសុវត្ថិភាពនៃផលិតផលជលផល ដល់អ្នកនេសាទ អ្នកកែច្នៃ និងពាណិជ្ជករនាំចេញ ត្រូវបានកែលម្អ | ២.១. ផលិតផលវារីវប្បកម្ម កើនឡើង ១៥% ក្នុងមួយឆ្នាំ ដល់ ១០២ ពាន់តោន នៅត្រឹមដំណាច់ឆ្នាំ២០១៥<br>៣.១. សេចក្តីព្រាងអនុស្សារណៈយោគយល់ ចំនួន ១ រវាងអង្គភាពមានសមត្ថកិច្ចនៃប្រទេសជិតខាង ស្តីពីការត្រួតពិនិត្យផលិតផលជលផល ដើម្បីជំរុញការនាំចេញស្របច្បាប់<br>៣.២ ផែនការយុទ្ធសាស្ត្រជាតិស្តីពីខ្សែសង្វាក់តម្លៃក្នុងវិស័យជលផល ត្រូវបានរៀបចំ និងអនុម័តដោយក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីការកែទម្រង់ជលផល នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br>៣.៣. ស្តង់ដារជាតិចំនួន ៣ គឺ : ប្រហុក ត្រីងៀត និងបង្គារបង្កក ត្រូវបានអនុម័តដោយវិទ្យាស្ថានស្តង់ដារកម្ពុជា |
| **វិស័យដីធ្លី**<br>ការគ្រប់គ្រង ការបែងចែក និងរដ្ឋបាលដីធ្លី ប្រកបដោយសមភាព តម្លាភាព ប្រសិទ្ធភាព និងចីរភាព ដើម្បីរួមចំណែកសម្រេចគោលដៅជាតិក្នុងការកាត់បន្ថយភាពក្រីក្រ និងធានាបាននូវសន្តិសុខស្បៀង ការពារបរិស្ថាន និងធនធានធម្មជាតិ និងសមភាពខាងយេនឌ័រ | ១. គោលនយោបាយគ្រប់ជ្រុងជ្រោយស្តីពីដីធ្លី និងក្របខណ្ឌស្តីពីការរៀបចំដែនដី និងផែនការទីក្រុង ត្រូវបានរៀបចំបញ្ចប់ បន្ទាប់ពីកិច្ចពិគ្រោះយោបល់ទូលំទូលាយជាមួយភាគីពាក់ព័ន្ធ<br>២. ដំណើរការចុះបញ្ជីដីធ្លី ត្រូវបានពង្រឹង ដោយផ្តោតលើសហគមន៍ជនជាតិដើមភាគតិច គ្រួសារក្រីក្រ និងងាយរងគ្រោះ ព្រមទាំងជៀសពីការផ្លាស់ចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងតំបន់ទីក្រុង ទីប្រជុំជន | ១.១. គោលនយោបាយដីធ្លី (សៀវភៅស) ត្រូវបញ្ចប់ និងអនុម័តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រឹមដំណាច់ខែ ធ្នូ ឆ្នាំ ២០១៤<br>១.២. ផ្នែកស្តីពីការគ្រប់គ្រងដែនដី និងផែនការទីក្រុង នៃច្បាប់ស្តីពីការរៀបចំដែនដី ផែនការទីក្រុង និងសំណង់ នឹងត្រូវបានតាក់តែង និងពិគ្រោះយោបល់ជាសាធារណៈ ហើយត្រូវរៀបចំបញ្ចប់សេចក្តីព្រាងដោយក្រសួង ដ.ន.ស ត្រឹមដំណាច់ខែ ធ្នូ ឆ្នាំ ២០១៥<br>១.៣. គោលនយោបាយជាតិស្តីពីលំនៅឋាន ត្រូវបានអនុម័តនៅខែ ឧសភា ឆ្នាំ ២០១៤<br>២.១. សហគមន៍ជនជាតិដើមភាគតិចចំនួន ១០ យ៉ាងតិច ក្នុង ១ ឆ្នាំ បានចុះបញ្ជីដីជាសមូហភាព<br>២.២. វិធានការការពារបណ្តោះអាសន្ន ត្រូវបានផ្តល់ជូនសហគមន៍ជនជាតិដើមភាគតិច ដែលបានដាក់ពាក្យស្នើសុំ<br>២.៣. សេចក្តីណែនាំជាក់លាក់ត្រូវដាក់ឱ្យអនុវត្ត ដើម្បីប្តូរប័ណ្ណកម្មសិទ្ធិឯកជនរបស់ជនជាតិភាគតិច មកជាប័ណ្ណកម្មសិទ្ធិសមូហភាព |

| [illegible] ២០១៤-២០១៨ | [illegible] ២០១៤-២០១៨ | [illegible] ២០១៤-២០១៨ |
|---|---|---|
| | ៣. ការពន្លឿនការអនុវត្តកម្មវិធីបែងចែកដីសម្បទានសង្គមកិច្ចទូទាំងប្រទេស ដោយផ្អែកលើសន្ទិធិដីរដ្ឋ (សារពើពន្ធដីរដ្ឋ) | ២.៤. អនុក្រឹត្យលេខ ៨៣ ត្រូវបានអនុវត្ត<br>២.៥. ពង្រឹងសមត្ថភាពរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក និងខេត្ត ដើម្បីដោះស្រាយវិវាទដីធ្លីដែលកើតឡើងតាមមូលដ្ឋាន<br>៣.១. ផ្សព្វផ្សាយជាសាធារណៈ នូវទិន្នន័យដីរដ្ឋដែលមានស្រាប់ សម្រាប់សម្បទានដីសង្គមកិច្ចដែលត្រូវបែងចែក ហើយដែលពាក់ព័ន្ធនឹងគម្រោងសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ |
| **វិស័យមីន**<br>កម្មវិធីជាតិសកម្មភាពមីន ដែលផ្តល់អត្ថប្រយោជន៍សម្រាប់សន្តិសុខមនុស្សជាតិ និងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច និងការអភិវឌ្ឍសហគមន៍ ដែលរងផលប៉ះពាល់ដោយសារមីន និង ស.ផ.ស | ១. ដីដែលបានបោសសម្អាតមីនរួច ត្រូវបានប្រើប្រាស់ដោយអ្នកទទួលផល ប្រកបដោយប្រសិទ្ធភាព សម្រាប់លើកកម្ពស់ជីវភាពរស់នៅ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ<br>២. កាត់បន្ថយចំនួនជនរងគ្រោះដោយសារមីន និង ស.ផ.ស<br>៣. ជនរងគ្រោះដោយសារមីន បានយល់ដឹងអំពីសិទ្ធិរបស់ពួកគេ និងបានទទួលសេវាប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងជីវភាពរស់នៅ | ១.១. រំដោះផ្ទៃដីមានមីន និង ស.ផ.ស ឱ្យបាន ៩.០០០ ហិកតា យ៉ាងតិច ក្នុងមួយឆ្នាំ<br>១.២. ផ្ទៃដីដែលបានសម្អាតមីនរួចទាំងអស់ ត្រូវបានប្រើប្រាស់ដោយអ្នកទទួលផល សម្រាប់លើកកម្ពស់ជីវភាពរស់នៅ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ<br>១.៣. ក្រុមការងារផែនការសកម្មភាពមីនគ្រប់ខេត្ត ទទួលការបណ្តុះបណ្តាលអំពីសិទ្ធិលើដីធ្លី<br>២.១. ចំនួនជនរងគ្រោះដោយសារមីន និង ស.ផ.ស ត្រូវបានកាត់បន្ថយឱ្យនៅតិចជាង ១០០ នាក់ក្នុងមួយឆ្នាំ<br>៣.១. ការចុះអង្កេតអំពីគុណភាពនៃជីវភាពរស់នៅរបស់ជនរងគ្រោះ នៅតាមភូមិចំនួន ១.០០០<br>៣.២. ជនបង្គោលរបស់អាជ្ញាធរមីនកម្ពុជា ចូលរួមជាទៀងទាត់ និងប្រកបដោយប្រសិទ្ធភាព ក្នុងវេទិកានានា និងបណ្តាញជនពិការដោយសារមីន នៅថ្នាក់ជាតិ និងនៅថ្នាក់អន្តរជាតិ |

**<u>ចតុកោណទី ២ : ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត</u>** - អាទិភាពរបស់យុទ្ធសាស្ត្រចតុកោណ (កឋាខ័ណ្ឌទី ១៤-២) គឺ ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីកសាងប្រព័ន្ធឡូជីស្ទីកដ៏រស់រវើក តាមរយៈការសាងសង់បណ្តាញដឹកជញ្ជូនពហុសណ្ឋាន ក្នុងគោលដៅធានាឱ្យបាននូវការតភ្ជាប់ផ្ទៃក្នុងប្រទេស និងការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ព្រមទាំងឆ្លើយតបបានទៅនឹងការរីកចំរើន ផ្នែកឧស្សាហូបនីយកម្ម ដែលនឹងនាំមកនូវ ១) ការកាត់បន្ថយថ្លៃដឹកជញ្ជូន ២) ការបង្កើនភាពអាចទុកចិត្តបាន និងភាពស័ក្តិសិទ្ធិ ៣) ការពង្រឹងភាពប្រកួតប្រជែង ៤) ការបង្កើនការវិនិយោគ និងពាណិជ្ជកម្ម ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពក្នុងការពង្រីកសមត្ថភាពផលិត និងផ្គត់ផ្គង់ថាមពលពីប្រភព ដែលមានតម្លៃកាន់តែទាប និងពង្រីកបណ្តាញចែកចាយ សំដៅធានាសន្តិសុខថាមពល ភាពអាចទុកចិត្តបានក្នុងការផ្គត់ផ្គង់ថាមពល ព្រមទាំងថ្លៃសមរម្យ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ ។ ក្នុងការលើកកម្ពស់វិស័យហេដ្ឋារចនាសម្ព័ន្ធ សមាសធាតុសំខាន់ៗត្រូវបានកំណត់ ដូចតទៅ ÷ ក) ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង ខ) ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ គ) ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ឃ) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ។

| លទ្ធផល ២០១៤-២០១៨ | ធាតុចេញ ២០១៤-២០១៥ | សូចនាករសម្រេចបាន ២០១៤-២០១៥ |
|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធ និង សមាហរណកម្មក្នុងតំបន់<br><br>ការកែលម្អប្រព័ន្ធដឹកជញ្ជូនប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ការទទួលបានទឹកប្រើប្រាស់ផ្ទាល់ពីប្រព័ន្ធចែកចាយទឹក និងបញ្ចប់ការកសាងបណ្តាញចែកចាយអគ្គិសនីរដ្ឋ ដើម្បីពង្រឹងសុខុមាលភាពរបស់ប្រជាជន និងការប្រកួតប្រជែងរបស់ប្រទេស | ១. កែលម្អប្រព័ន្ធដឹកជញ្ជូន ÷<br>១.១. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងកែលម្អ និងពង្រីកផ្លូវក្រាលកៅស៊ូ និងពង្រីកកំពង់ផែ<br>១.២ ការរៀបចំ និងអនុវត្តគោលនយោបាយ ដូចជា÷ ច្បាប់កំពង់ផែ និងផែនការអភិវឌ្ឍផ្លូវល្បឿនលឿន តាមកំណាត់ផ្លូវអាទិភាព<br><br>២. ការកែលម្អបណ្តាញចែកចាយអគ្គិសនីរដ្ឋ÷<br>២.១. ការកសាងបណ្តាញចែកចាយអគ្គិសនី ១១៥ គីឡូវ៉ាត់ ពីរាជធានីភ្នំពេញ ទៅខេត្តស្វាយរៀង និងពីគិរីរម្យ ៣ ទៅស្រែអំបិល និងពីស្ទឹងហាវ ទៅខេត្តព្រះសីហនុ<br>២.២ ការកសាងបណ្តាញចែកចាយអគ្គិសនី ២៣០ គីឡូវ៉ាត់ ជុំវិញរាជធានីភ្នំពេញ និងពីរាជធានីភ្នំពេញ ទៅកំពង់ចាម ពីអូសំ- ភារីអគ្គិសនីឫស្សីជ្រុំ- ភារីអគ្គិសនីតាតៃ និងពីខេត្តក្រចេះ ទៅខេត្តកំពង់ចាម | នៅត្រឹមដំណាច់ឆ្នាំ ២០១៥ ÷<br>១.១. ចាប់ផ្តើមសកម្មភាពសាងសង់តាមផ្លូវជាតិសំខាន់ៗ : ផ្លូវជាតិលេខ ១ (រាជធានីភ្នំពេញ-ខេត្តកណ្តាល) ផ្លូវជាតិលេខ ២ (ខេត្តកណ្តាល- តាកែវ) ផ្លូវជាតិលេខ ៣ (កំពត-វាលរេញ) ផ្លូវជាតិលេខ ៥ (ព្រែកក្តាម- សេរីសោភ័ណ) និងផ្លូវជាតិលេខ ៧ (កំពង់ចាម- ក្រចេះ)<br>១.២. ពង្រីកកំពង់ផែព្រះសីហនុ<br>១.៣. រៀបចំច្បាប់កំពង់ផែ<br>១.៤. រៀបចំផែនការអភិវឌ្ឍន៍ផ្លូវល្បឿនលឿន តាមកំណាត់ផ្លូវអាទិភាព<br>២.១. បញ្ចប់ការសាងសង់បណ្តាញចែកចាយអគ្គិសនី ដូចបានកំណត់នៅក្នុងធាតុចេញ |

**ចតុកោណទី៣ : ការអភិវឌ្ឍវិស័យឯកជន និងការងារ** – អាទិភាពរបស់យុទ្ធសាស្ត្រចតុកោណ (កឋាខ័ណ្ឌទី ១៤-៤) ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ...... ៤) ការបង្កើនភាពទាក់ទាញចំពោះការវិនិយោគ ក្នុងនោះមានការកាត់បន្ថយថ្លៃដើម និងរារាំងធុរកិច្ច ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ ការពង្រឹងភាពជឿទុកចិត្ត និងភាពអាចប៉ាន់ប្រមាណបានក្នុងការធ្វើធុរកិច្ច ព្រមទាំងការផ្តោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស ។ ក្នុងការលើកកម្ពស់វិស័យឯកជន ស្នូលសមាសធាតុសំខាន់ៗត្រូវបានកំណត់ រួមមាន ÷ (ក) ការពង្រឹងវិស័យឯកជន និងជំរុញការវិនិយោគ និងធុរកិច្ច (ខ) ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម (គ) ការអភិវឌ្ឍទីផ្សារការងារ (ឃ) ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ ។

| លទ្ធផល ២០១៤-២០១៨ | ធាតុចេញ ២០១៤-២០១៨ | សូចនាករធាតុចេញ ២០១៤-២០១៥ |
|---|---|---|
| **ការអភិវឌ្ឍវិស័យឯកជន**<br>១. លំហូរពាណិជ្ជកម្មត្រូវបានបង្កើន តាមរយៈការធ្វើសាមញ្ញកម្មនីតិវិធីតាមច្រកព្រំដែន និងការបង្កើនតម្លាភាពនៃការអនុវត្តច្បាប់ពាណិជ្ជកម្ម និងច្បាប់វិនិយោគ<br>២. បរិស្ថានធុរកិច្ចមានភាពកាន់តែប្រសើរឡើង ដែលជាលទ្ធផលនៃការកែទម្រង់ក្របខណ្ឌគតិយុត្តិ | ១. ការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្ម ដល់ភ្នាក់ងារសំខាន់ៗនៅតាមច្រកព្រំដែន នឹងពង្រឹងតម្លាភាព និងកែលម្អការបំពេញបែបបទ ទាំងពេលវេលា ទាំងចំណាយ<br>២. បង្កើនការវិនិយោគក្នុងស្រុក ហើយចំនួនការងារជាច្រើនត្រូវបានបង្កើតឡើង | ១.១. នីតិវិធីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងតាមអនឡាញ ត្រូវបានអនុវត្តដោយភ្នាក់ងារនៅតាមច្រកព្រំដែន ចំនួន ២ (ក្រៅពីគយ) និងនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម នៅត្រឹមដំណាច់ឆ្នាំ ២០១៤<br>២.១. លេខរៀងចំណាត់ថ្នាក់ធុរកិច្ច ត្រូវបានកែលម្អ ឱ្យថយចុះ ១០ថ្នាក់ |
| ចតុកោណទី ៤ : **ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស** - អាទិភាពរបស់យុទ្ធសាស្ត្រចតុកោណ (កម្មវិធីណទី ១៤-១) ការអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហរ តាមរយៈ ១) ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើនតម្លៃបន្ថែមខ្ពស់ ២) ការរៀបចំក្របខណ្ឌគតិយុត្ត និងកសាងស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងចំណុចទី១ខាងលើ ៣) ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមនៅក្នុងកិច្ចការនេះ និង ៤) ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។ ក្នុងការលើកកម្ពស់ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស សមាសធាតុសំខាន់ៗត្រូវបានកំណត់ រួមមាន ៖ ក) ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស ខ) ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ គ) ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឃ) ការជំរុញអនុវត្តគោលនយោបាយជាតិ ប្រជាជន និងសមភាពយេនឌ័រ ។ | | |
| **វិស័យអប់រំ**<br>អត្រាបញ្ចប់ការសិក្សានៅកម្រិតអប់រំមូលដ្ឋាន កើនឡើង | ១. អត្រាឡើងថ្នាក់នៅបឋមសិក្សា កើនឡើង ពិសេសនៅក្នុងថ្នាក់ដំបូង<br>២. ការចូលរៀននៅមធ្យមសិក្សាបឋមភូមិ កើនឡើង និងអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិថយចុះ និងត្រួតពិនិត្យ | ១.១. ភាគរយកុមារអាយុ ៥ ឆ្នាំ នៃកម្មវិធីអប់រំកុមារតូច កើនឡើងពី ៥៦,៦ % ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៦៦ % ក្នុងឆ្នាំសិក្សា ២០១៣-១៤<br>២.១. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ កើនឡើងពី ៥៣,៦ % ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៦៦,៩ % ក្នុងឆ្នាំសិក្សា២០១៤-១៥<br>២.២. អត្រាតជំរុញនៅថ្នាក់ទី ៩ កើនពី ៣០,៧ % ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៣៥ % ក្នុងឆ្នាំសិក្សា ២០១៤-១៥<br>២.៣. ការវិភាជន៍ថវិកាសម្រាប់ការអប់រំមូលដ្ឋាន កើនឡើងពី ៦៨,៥ % ក្នុងឆ្នាំសិក្សា ២០១៣-១៤ ដល់ ៦៩,២% ក្នុងឆ្នាំសិក្សា ២០១៤-១៥ |

| គោលដៅ<br>២០១៤-២០១៨ | លទ្ធផល<br>២០១៤-២០១៥ | សូចនាករលទ្ធផល<br>២០១៤-២០១៥ |
|---|---|---|
| | | ២.៤. អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ថយចុះពី ២១,២% ក្នុងឆ្នាំសិក្សា ២០១២-១៣ មកត្រឹម ១៩ % ក្នុងឆ្នាំសិក្សា ២០១៤-១៥<br>២.៥. ចំនួនសិស្សអាហារូបករណ៍កើនឡើងដល់ ៩៥.០០០ នាក់ ក្នុង ១ ឆ្នាំ សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ |
| | ៣. លទ្ធផលសិក្សាតាមមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា នៅថ្នាក់ទី ៣ និងថ្នាក់ទី ៦ មានភាពប្រសើរឡើង | ៣.១. លទ្ធផលនៃការវាយតម្លៃការសិក្សាថ្នាក់ជាតិ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា នៅថ្នាក់ទី ៣ និងថ្នាក់ទី ៦ សម្រាប់រៀបចំគោលនយោបាយ<br>៣.២. ផលធៀបសិស្សបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ទទួលបានសៀវភៅសិក្សាគោល<br>- ថ្នាក់ទី១-៣ កើនពី ២,៩ ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៣,០ ក្នុងឆ្នាំសិក្សា ២០១៤-១៥<br>- ថ្នាក់ទី៤-៦ កើនពី ៣,៨ ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៣,៩ ក្នុងឆ្នាំសិក្សា ២០១៤-១៥<br>- ថ្នាក់ទី៧-៩ កើនពី ៦,០ ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៧,០ ក្នុងឆ្នាំសិក្សា ២០១៤-១៥ |
| **វិស័យសុខាភិបាល**<br>ប្រព័ន្ធសុខាភិបាលជាតិមានដំណើរការល្អ និងធានាចីរភាព បង្កើនបានលទ្ធផលល្អប្រសើរ ក្នុងផ្នែកអនាម័យ សុខភាព អាហារូបត្ថម្ភ និងសុខុមាលភាព សម្រាប់ប្រជាជនកម្ពុជា ពិសេសប្រជាជនក្រីក្រ និងជនងាយរងគ្រោះ រួមមានស្ត្រី និងកុមារ | ១. ធ្វើឱ្យប្រសើរឡើង នូវសុខភាពបន្តពូជ សុខភាពមាតា កុមារ និងទារក តាមរយៈការពង្រឹងគុណភាព និងភាពស័ក្តិសិទ្ធិនៃសេវាថែទាំសុខភាព ÷<br>១.១. ពង្រីកការគ្របដណ្តប់ការសម្រាលកូនដោយគ្រូពេទ្យជំនាញ នៅតាមមូលដ្ឋានសុខាភិបាល<br>១.២. ពង្រីកសេវាកម្មពិគ្រោះយោបល់ស្តីពីជម្រើសនៃការពន្យាកំណើត<br>២. ធ្វើឱ្យប្រសើរឡើង នូវស្ថានភាពអាហារូបត្ថម្ភ តាមរយៈបង្កើនការផ្តល់ប្រឹក្សាអំពីការបំបៅទារកដោយទឹកដោះម្តាយតែមួយគត់ និងការផ្តល់អាហារបន្ថែមសមស្រប | ១.១. ការសម្រាលកូនដោយគ្រូពេទ្យជំនាញ នៅតាមមូលដ្ឋានសុខាភិបាល កើនដល់ ៨៣ % នៅឆ្នាំ ២០១៤ និង ៨៥ % នៅឆ្នាំ ២០១៥ (លទ្ធផល ៨០ % នៅឆ្នាំ ២០១៣ និងទិន្នន័យមូលដ្ឋាន ៧៦.០៦ % ឆ្នាំ២០១២)<br>១.២. ភាគរយមណ្ឌលសុខភាពមួយមានឆ្មបយ៉ាងតិច ១ រូប កើនដល់ ៨៥ % នៅឆ្នាំ ២០១៤ និង 100% នៅឆ្នាំ ២០១៥ (លទ្ធផល ៧៥% នៅឆ្នាំ ២០១៣ និងទិន្នន័យមូលដ្ឋាន ៦៦% នៅឆ្នាំ ២០១២)<br>១.៣. អត្រាពន្យាកំណើត កើនដល់ ៣៧ % នៅឆ្នាំ ២០១៤ និង ៤០ % ឆ្នាំ ២០១៥ (លទ្ធផល ៣៤ % នៅឆ្នាំ២០១៣ និងទិន្នន័យមូលដ្ឋាន ៣០,៤៥ % នៅឆ្នាំ ២០១២)<br>២.១. ភាគរយនៃការបំបៅទារកដោយទឹកដោះម្តាយតែមួយមុខគត់ រហូតដល់ ៦ ខែ កើនដល់ ៧៥% នៅឆ្នាំ ២០១៤ និង ៧៦% នៅឆ្នាំ ២០១៥ (ទិន្នន័យមូលដ្ឋាន ៧៤% នៅឆ្នាំ ២០១០) |

| គោលដៅ<br>២០១៤-២០១៨ | លទ្ធផល<br>២០១៤-២០១៥ | សូចនាករសមិទ្ធកម្ម<br>២០១៤-២០១៥ |
|---|---|---|
| **ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ**<br><br>ការគ្របដណ្តប់ និងការប្រើប្រាស់ទឹកស្អាត និងអនាម័យនៅជនបទ កើនឡើង (គោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺ ៦០% សម្រាប់ការប្រើប្រាស់ទឹកស្អាត និង ៦០% សម្រាប់ការលើកកម្ពស់អនាម័យ) | ១. កម្មវិធីជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ត្រូវបានរៀបចំ ដោយបញ្ជាក់អំពីមុខងារ និងតួនាទីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br><br>២. ធនធានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ កើនឡើង<br><br>៣. ប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីទឹកស្អាត និងអនាម័យនៅជនបទ ត្រូវបានបង្កើត និងអនុវត្ត | ១.១. កម្មវិធីជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ត្រូវបាន រៀបចំ នៅត្រឹមដំណាច់ខែ ធ្នូ ឆ្នាំ ២០១៤ (ការរៀបចំអនុវត្ត និងថវិកា)<br>១.២. ផែនការប្រតិបត្តិ ដោយកំណត់សកម្មភាពអាទិភាព ទិសដៅ និងការប៉ាន់ស្មានអំពីតម្រូវការថវិកា ត្រូវបានរៀបចំ នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br>១.៣. ឯកសារគាំទ្រនានា សម្រាប់អនុវត្តកម្មវិធីជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ត្រូវបានរៀបចំ នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br><br>២.១. ធនធានសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ កើនឡើងយ៉ាងតិច ១០% ក្នុងមួយឆ្នាំ<br>២.២. ថវិកាតាមកម្មវិធី សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ត្រូវបានរៀបចំដោយឡែកពីគ្នា ហើយលទ្ធផលប្រចាំឆ្នាំត្រូវបានចែករំលែកឱ្យគ្នាទៅវិញទៅមក<br><br>៣.១. ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានបង្កើត នៅត្រឹមដំណាច់ខែ ធ្នូ ឆ្នាំ ២០១៤<br>៣.២. ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ត្រីពាក់ព័ន្ធ ទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងប្រព័ន្ធព័ត៌មាន និងការប្រមូលទិន្នន័យ នៅត្រឹមដំណាច់ខែ មិថុនា ឆ្នាំ២០១៥ |

| លទ្ធផល ២០១៤-២០១៨ | ទិន្នផល ២០១៤-២០១៥ | សូចនាករទិន្នផល ២០១៤-២០១៥ |
|---|---|---|
| **ជម្ងឺអេដស៍**<br>ការឆ្លងថ្មី នូវមេរោគអេដស៍ និងការស្លាប់ដោយសារជម្ងឺអេដស៍ មានការធ្លាក់ចុះ និងអត្រាប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ កើនឡើងដល់ ៩០% នៅឆ្នាំ ២០១៨ (លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលឱសថ ត្រូវធ្វើឡើងក្នុងករណីដែលកោសិកាស៊ីឌីហ្វូរស្មើ ឬ តិចជាង ៥០០ cc/mm³) | ១. ក្រុមប្រឈមមុខខ្ពស់ បានគ្របដណ្តប់ប្រមាណ ៨០% | ១.១. ចំនួនអ្នកចាក់គ្រឿងញៀន PWID ដែលបានគ្របដណ្តប់ដោយ : ក) កម្មវិធីម្ជុលសឺរ៉ាំង ខ) កម្មវិធីចុះអប់រំផ្ទាល់- ផ្លាស់ប្តូរការប្រព្រឹត្ត និងការផ្តល់សម្ភារៈអប់រំផ្សព្វផ្សាយ BCC/IEC និង គ) កម្មវិធីចែកចាយស្រោមអនាម័យ មានចំនួន ៨៨៨ នាខែ ធ្នូ ឆ្នាំ ២០១៥<br>១.២. ចំនួនបុរសរួមភេទជាមួយបុរស ដែលបានគ្របដណ្តប់ដោយអន្តរាគមន៍ចុះផ្ទាល់ ម្តង ក្នុង ១ ត្រីមាស ដោយ : ក) អន្តរាគមន៍ចែកចាយសម្ភារៈអប់រំផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ ខ) អន្តរាគមន៍ចែកចាយស្រោមអនាម័យ មានចំនួន ១៨.៣៤៥ នាខែធ្នូ ឆ្នាំ២០១៥<br>១.៣. ចំនួនស្ត្រីក្នុងសេវាកំសាន្ត ដែលបានគ្របដណ្តប់ដោយអន្តរាគមន៍ យ៉ាងហោចណាស់ ម្តង ក្នុង ១ ត្រីមាស ដោយ : ក) អន្តរាគមន៍ចែកចាយសម្ភារៈអប់រំ ផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ ខ) អន្តរាគមន៍ចែកចាយស្រោមអនាម័យ មានចំនួន ៣៦.៧៨២ នាខែ ធ្នូ ឆ្នាំ ២០១៥ |
| | ២. ចំនួនជនផ្ទុកមេរោគអេដស៍ ដែលទទួលឱសថប្រឆាំងមេរោគអេដស៍ នៅត្រឹមដំណាច់ឆ្នាំ ២០១៥<br>២.១. បើសន្មត់ប្រើគោលការណ៍ CD4< 350 cc/mm³ ការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍នឹងកើនដល់ ៨៧% សម្រាប់មនុស្សពេញវ័យ និង ៩៥% សម្រាប់កុមារ<br>២.២. ការសន្មត់ប្រើគោលការណ៍ CD4< 500 cc/mm³ ការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍នឹងកើនដល់ ៨០% សម្រាប់មនុស្សពេញវ័យ និង ៩៥% សម្រាប់កុមារ | ២.១. ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ ជាមនុស្សពេញវ័យ និងកុមារ ដែលទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺ ៨៣ % បើអនុវត្តគោលការណ៍ CD4< 350 cc/mm³ ។ បើអនុវត្តគោលការណ៍ CD4< 500 cc/mm³ កម្រិតគ្របដណ្តប់ការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ គឺ ៧២% |
| | ៣. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្លើយតបមេរោគអេដស៍ និងជម្ងឺអេដស៍ លើកទី ៤ (NSP4) ត្រូវបានរៀបចំឡើង ហើយផែនការកៀរគរធនធានត្រូវបានអនុម័ត | ៣.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី ៤ (NSP4) រួមទាំងគម្រូវការថវិកា ត្រូវបានរៀបចំ ដោយឈរលើភស្តុតាងជាក់ស្តែង និងបទដ្ឋានអន្តរជាតិ ត្រូវបានរៀបចំ និងត្រូវបានអនុម័តដោយភាគីពាក់ព័ន្ធទាំងអស់<br>៣.២. ផែនការកៀរគរធនធាន រយៈពេល ៥ឆ្នាំ ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូក្រៅប្រទេស សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ប្រកបដោយចីរភាព |

| គោលដៅ ២០១៤-២០១៨ | អាទិភាព ២០១៤-២០១៨ | សូចនាករគន្លឹះ ២០១៤-២០១៨ |
|---|---|---|
| **ការគាំពារសង្គម សុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ**<br><br>ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការគាំពារសង្គមសម្រាប់ជនក្រីក្រ ជនដែលងាយរងគ្រោះអសន្តិសុខស្បៀង និងជនងាយរងគ្រោះ នៅកម្ពុជា ត្រូវបានកែលម្អ តាមរយៈប្រព័ន្ធសម្របសម្រួល និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ | ១. យុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់អនុវត្តប្រកបដោយសុខដុមនីយកម្ម និងប្រសិទ្ធភាព ត្រូវបានបង្កើតឡើង ដោយមានការគាំទ្រខាងថវិកា<br><br>២. ផែនការសកម្មភាពជាតិគាំពារសង្គម ត្រូវបានអនុម័ត ដែលអាចពង្រីកវិសាលភាពកម្មវិធីគាំពារសង្គម ប្រកបដោយការសម្របសម្រួល ប្រសិទ្ធភាព និងប្រសិទ្ធផល | ១.១. ឯកសារយុទ្ធសាស្ត្រជាតិ ដូចជាយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ផែនទីបង្ហាញផ្លូវរបស់ក្រសួងសុខាភិបាលសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ (២០១៤-២០២០) និងផែនការវិនិយោគសម្រាប់អាហារូបត្ថម្ភ ត្រូវបានបង្កើតឡើង និងទទួលបានការអនុម័ត ហើយគោលការណ៍ណែនាំនានាដែលមានស្រាប់ ត្រូវបានពង្រឹងការអនុវត្តដោយរាជរដ្ឋាភិបាល<br>១.២. ការពង្រឹងការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ការវិភាគទិន្នន័យ និងការសម្របសម្រួល នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអង្កេតតាមដានលើស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ<br>២.១. ថវិកាជាតិសម្រាប់កម្មវិធីគាំពារសង្គម កើនឡើងយ៉ាងតិច ១០% ប្រចាំឆ្នាំ<br>២.២. យន្តការផ្តល់សេវាសង្គម និងយន្តការសម្របសម្រួលនៃកម្មវិធីគាំពារសង្គម ត្រូវបានរៀបចំ<br>២.៣. ផែនទីគោលសម្រាប់ពង្រីកវិសាលភាពប្រព័ន្ធសន្តិសុខសង្គម ត្រូវបានរៀបចំ |
| **សមភាពយេនឌ័រ**<br><br>ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈការបង្កើត និងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ កម្មវិធីជាតិនានាសម្រាប់បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការទទួលបានកិច្ចគាំទ្រស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការទទួលបានកិច្ចការពារផ្លូវច្បាប់កាន់តែប្រសើរ និងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងការដឹកនាំ និងការធ្វើសេចក្តីសម្រេច | ១. នារីរតនៈទី ៤ និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវបានដាក់ឱ្យអនុវត្ត<br><br>២. កម្មវិធីគន្លឹះ ២ គឺ ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើហិង្សាលើស្ត្រី ដំណើរការពេញលេញ តាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី : ការគាំទ្រខាងស្ថាប័ន ការបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងការអនុវត្ត<br>៣. ការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ កើនឡើង ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា | ១.១. បញ្ចប់ និងដាក់ឱ្យប្រើប្រាស់នូវលទ្ធផលនៃការវាយតម្លៃយេនឌ័រនៅកម្ពុជា ឆ្នាំ ២០១៤ និងនារីរតនៈ ទី ៤ ហើយផ្សព្វផ្សាយតាមក្រសួងនិងស្ថាប័នតាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ និងផ្តល់ថវិកាចាំបាច់សម្រាប់អនុវត្ត<br>១.២. រៀបចំបញ្ចប់គោលនយោបាយជាតិស្តីពីសមភាព និងអនុម័តដោយគណៈរដ្ឋមន្ត្រី<br>២.១. បញ្ចប់ការអនុវត្តក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឆ្នាំ ២០១៥<br>២.២. អនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី សម្រាប់ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយមានធនធានគ្រប់គ្រាន់ និងអនុវត្តកម្មវិធីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី<br>២.៣. អនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីសម្រាប់ផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើហិង្សាលើស្ត្រី ដោយមានធនធានគ្រប់គ្រាន់ និងអនុវត្តកម្មវិធីនេះ<br>៣.១. សមាមាត្រស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ (ចាប់ពីអនុប្រធានការិយាល័យ រហូតដល់អគ្គនាយក) កើនឡើងពី ១៨% ក្នុងឆ្នាំ ២០១២ ដល់ ២៥% នៅឆ្នាំ ២០១៨ |

| លទ្ធផល ២០១៤-២០១៨ | ធាតុចេញ ២០១៤-២០១៨ | សូចនាករគោលដៅ ២០១៤-២០១៨ |
|---|---|---|
| | | ៣.២. សមាមាត្រស្ត្រីនៅក្នុងប្រព័ន្ធតុលាការ កើនឡើងពី ១៧ % ជាមេធាវី និង ១៤ % ជាចៅក្រម ដល់ ២០ % ជាមេធាវី និង ១៥ % ជាចៅក្រម នៅឆ្នាំ២០១៨<br>៣.៣. ភាគរយរបស់ស្ត្រីជាបេក្ខជនឈរឈ្មោះបោះឆ្នោតថ្នាក់ជាតិ កើនឡើងពី ១៩ % ទៅ ២៥ % នៅឆ្នាំ ២០១៨ និងថ្នាក់ក្រោមជាតិ កើនឡើងពី ២៥ % ទៅ ៣០ % នៅឆ្នាំ ២០១៧ |